# ឧប្បត្តិហេតុ

នៃ

# ព្រះត្រៃបិដកប្រែ

www.elibraryofcambodia.org

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ភ្នំពេញ

ព.ស. ២៥១៤ គ.ស. ១៩៧០

294.
307596
LEN

www.elibraryofcambodia.org

# ឧប្បត្តិហេតុ

នៃ

ព្រះត្រៃបិដកប្រែ

ប្រមូលចងក្រង

ដោយ

**លោក ហ៊ប អាន**

នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

សម្តេចព្រះពោធិវង្ស ហួត តាត

អធិបតីក្រុមជំនុំព្រះត្រៃបិដក សាកលវិទ្យាធិការនៃ

ពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជ និង អគ្គាធិការ

ពុទ្ធិកសិក្សា កម្ពុជរដ្ឋ

ពិនិត្យកែសម្រួល

ផ្សាយក្នុងឱកាស ពិធីបុណ្យ សម្ពោធឆ្លងព្រះត្រៃបិដក

ថ្ងៃអង្គារ ១៥ កើតខែចេត្រ ឆ្នាំរកសំរិទ្ធិស័ក ព.ស. ២៥១២

ត្រូវនឹងថ្ងៃទី ១ ខែមករា គ.ស. ១៩៦៩

បោះពុម្ពលើកទី ២

ព.ស. ២៥១៤ គ.ស. ១៩៧០

www.elibraryofcambodia.org

National Library of Cambodia

00007851

www.elibraryofcambodia.org

# សេចក្ដីប្រារព្ធ

សៀវភៅ "ឧប្បត្តិហេតុនៃព្រះត្រៃបិដកប្រែ" នេះ វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ បានទទួលសេចក្ដីសុំអំពីសម្ដេចព្រះពោធិវង្ស(សព្វថ្ងៃព្រះអង្គឡើងព្រះឋានៈជាសម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយក គណៈមហានិកាយ) ឲ្យរៀបចំដើម្បីបោះពុម្ពចែកជាធម្មទាន ក្នុងឱកាសពិធីបុណ្យសម្ពោធឆ្លងព្រះត្រៃបិដក កាលពីថ្ងៃអង្គារ ១៤ កើត ខែចេត្រ ឆ្នាំរកាសំរិទ្ធិស័ក ព. ស. ២៥១២ ត្រូវនឹងថ្ងៃទី ១ ខែមេសា គ. ស. ១៩៦៩ ។

មកដល់ពេលដែល សម្ដេចព្រះសង្ឃរាជព្រះនាម **ជួន-ណាត** ទ្រង់សោយព្រះទិវង្គត (កាលពីថ្ងៃ ២៥ កញ្ញា ១៩៦៩) នេះ សម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយកជាអម្ចាស់ ក៏សព្វព្រះទ័យសុំឲ្យវិជ្ជាឋានចាត់ការបោះពុម្ពសៀវភៅនេះជាលើកទី ២ ដើម្បីទុកជាវជូនពុទ្ធបរិស័ទ ដែលមានសទ្ធាចង់ជាវចែកជាធម្មទានក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងចំពោះព្រះបរមសព ។ វិជ្ជាឋាន ក៏សម្រេចពិនិត្យមើលសៀវភៅនេះជាថ្មី ដោយបន្ថែមបន្ថយសេចក្ដីខ្លះ ហើយចាត់ការបោះពុម្ពតាមការសព្វព្រះទ័យរបស់សម្ដេចព្រះសង្ឃនាយកជាអម្ចាស់ ។

www.elibraryofcambodia.org

វិជ្ជាឋានយល់ថា ឯកសារនេះប្រាកដជាមានប្រយោជន៍ច្រើន ចំពោះពុទ្ធបរិស័ទ ។

ភ្នំពេញ ថ្ងៃទី ១៦ ធ្នូ ១៩៦៩

**ឈាង ហ៊័ប អាន**

នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

www.elibraryofcambodia.org



www.elibraryofcambodia.org

ព្រះករុណាព្រះបាទសម្តេចព្រះ **ស៊ីសុវត្ថិ មុនីវង្ស** អតីតព្រះចៅប្រទេសកម្ពុជា

ទ្រង់ប្រោសព្រះរាជទានឲ្យបង្កើតក្រុមជំនុំព្រះត្រៃបិដក ក្នុង ព. ស. ២៤៧៣ គ. ស. ១៩២៩

**ទ្រង់គ្រងរាជសម្បត្តិ** : ក្នុង គ. ស. ១៩២៧ ។

**ទ្រង់សោយទិវង្គត** : ក្នុង គ. ស. ១៩៤១ ។

www.elibraryofcambodia.org



www.elibraryofcambodia.org

សម្ដេចព្រះរាជអយ្យកោ វរចក្ររណរិទ្ធិ

**នរោត្ដម សុធារស**

អធិបតីក្រុមជំនុំសង្គហៈ ព្រះរាជវង្សានុវង្ស

សម្ដេចទ្រង់គង់ជាអធិបតី នៃ វិទ្យាឋានពុទ្ធសាសនបណ្ឌិត្យ តាំងពីថ្ងៃបង្កើតក្រសួងនេះឡើង

គឺ: ថ្ងៃ ២៥ មករា ព. ស. ២៤៧៣ គ. ស. ១៩៣០

www.elibraryofcambodia.org



www.elibraryofcambodia.org

ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សុរាម្រិត** អតីតព្រះចៅប្រទេសកម្ពុជា

**ទ្រង់ប្រសូត** : នៅទីក្រុងភ្នំពេញ ថ្ងៃទី ៦ មីនា ១៨៩៦ ។

**ទ្រង់ឡើងគ្រងរាជសម្បត្តិ** : នៅថ្ងៃព្រហស្បតិ៍ ១០ កើត ខែផល្គុន ឆ្នាំមមី ឆស័ក ព.ស.២៤៩៧ ត្រូវនឹងថ្ងៃទី ៣ មីនា ១៩៥៥ ។

**ទ្រង់សោយទិវង្គត** : នៅថ្ងៃអាទិត្យទី ៣ មេសា គ.ស. ១៩៦០ ក្នុងព្រះជន្មាយុ ៦៦ ព្រះវស្សា ។

www.elibraryofcambodia.org



www.elibraryofcambodia.org

សម្ដេចព្រះមហាក្សត្រិយានី **ស៊ីសុវត្ថិ មុនីវង្ស**

**កុសុមៈនារីរតន៍ សិរីវឌ្ឍនា** ព្រះមាតាជាតិ

**ទ្រង់ប្រសូត :** នៅក្រុងភ្នំពេញ ចតុម្មុខ នៅថ្ងៃសៅរ៍ ៩ រោច ខែចេត្រ ឆ្នាំរោង បញ្ចស័ក ព.ស. ២៤៤៨, ម.ស. ១៨២៦, ច.ស. ១២៦៦ ត្រូវនឹងថ្ងៃទី ៩ មេសា ១៩០៤។

www.elibraryofcambodia.org


www.elibraryofcambodia.org

ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន**

អតីតព្រះចៅប្រទេសកម្ពុជា

**ទ្រង់ប្រសូត** : នៅក្រុងភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ១៩២២ ។

**ទ្រង់សោយរាជសម្បត្តិ** : នៅថ្ងៃទី ២៣ ខែមេសា ១៩៤១ ។

**ទ្រង់ដាក់រាជសម្បត្តិ** : នៅថ្ងៃពុធ ៩ កើត ខែផល្គុន ឆ្នាំមមី ឆស័ក ព.ស. ២៤៩៨ ត្រូវនឹង ថ្ងៃទី ២ មីនា ១៩៥៥ ។

**បច្ចុប្បន្ន** : ព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជា ព្រះបិតាជាតិ ។

www.elibraryofcambodia.org



www.elibraryofcambodia.org

សម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ គណៈមហានិកាយ

## ជួន ណាត ជោតញ្ញាណោ

**ប្រសូត :** ថ្ងៃអង្គារ ១១ រោចខែផល្គុន ឆ្នាំវក ឆស័ក ព.ស. ២៤២៧ គឺថ្ងៃទី ១១ មិនា គ.ស. ១៨៨៣ នៅភូមិកំរៀង សង្កាត់រកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

**ព្រះសមណសក្តិ:** ព្រះមហាសុមេធាធិបតី សង្ឃនាយក គណៈមហានិកាយ ពី ព.ស. ២៤៩១ គ.ស. ១៩៤៨ ។ សម្ដេចព្រះសង្ឃរាជថ្នាក់ទី ១ គណៈមហានិកាយ ពី ព.ស. ២៥០២ គ.ស, ១៩៦៣ ។

**សោយទិវង្គត :** ថ្ងៃព្រហស្បតិ៍ ១៤ កើតខែភទ្របទ ឆ្នាំរកានក្សត្រឯកស័ក ព.ស. ២៥១៣ ត្រូវនឹងថ្ងៃទី ២៩ កក្កដា ១៩៦៩ ក្នុងព្រះជន្មាយុ ៨៦ ព្រះវស្សា ។

www.elibraryofcambodia.org



www.elibraryofcambodia.org

សម្តេចព្រះសុធម្មាធិបតី ព្រះសង្ឃនាយក គណៈធម្មយុត្តិកនិកាយ

**ទេព លឿង** គន្ធរោ

**ប្រសូត** : នៅថ្ងៃច័ន្ទ ៤ កើត ខែមិគសិរ ឆ្នាំមមែ បញ្ចស័ក ព.ស. ២៤២៦ គ.ស. ១៨៨៣ ក្នុងភូមិត្រពាំងស្នា (ហៅកោះក្រសល់) ឃុំលន្ទះ (ហៅរាមអណ្តើក) ស្រុកគិរីវង់ ខែត្រតាកែវ ។

**សមណសក្តិ** : ព្រះអង្គទទួលព្រះសមណសក្តិជាសម្តេចព្រះសុធម្មាធិបតី ព្រះសង្ឃនាយក គណៈធម្មយុត្តិកនិកាយ តាមព្រះរាជក្រឹត្យ លេខ ២០ រ.វ. ចុះថ្ងៃ ២៨ មេសា ព.ស, ២៥០៩ គ.ស. ១៩៦៦ ។

www.elibraryofcambodia.org



www.elibraryofcambodia.org

សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក គណៈមហានិកាយ

## ហួត តាត វជិរប្បញ្ញោ

- សាកលវិទ្យាធិការ នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ
- អគ្គាធិការនៃពុទ្ធិកសិក្សាកម្ពុជរដ្ឋ
- អតីតនាយកនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត
- អធិបតីនៃក្រុមជំនុំព្រះត្រៃបិដកបច្ចុប្បន្ន នៅវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ
- អតីតប្រធានពុទ្ធិកសមាគម មជ្ឈមណ្ឌលកម្ពុជរដ្ឋ

**ប្រសូត** : ថ្ងៃអាទិត្យ ១៥ កើត ខែបុស្ស ឆ្នាំរោង ចត្វាស័ក ព. ស. ២៤៣៤ គ. ស. ១៨៩១ នៅភូមិផ្សារឧដុង្គ សង្កាត់វាំងចាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។

- ព្រះអង្គទទួលព្រះសមណសក្តិជាសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ តាមព្រះរាជក្រឹត្យលេខ ២៩ រ.ក. ចុះថ្ងៃទី ២៧ កញ្ញា ១៩៦៩ ។

www.elibraryofcambodia.org



www.elibraryofcambodia.org

## សម្តេចព្រះធម្មលិខិត ល្វី ឯម

### អតីត អធិបតីក្រុមជំនុំព្រះត្រៃបិដក

សម្តេចគង់ជាអធិបតី នៃ ក្រុមជំនុំព្រះត្រៃបិដក ក្នុង គ. ស. ១៩២៩

**ប្រសូត** : ថ្ងៃចន្ទ ៥ កើត ខែពិសាខ ឆ្នាំរោង ទោស័ក ព. ស. ២៤២២ គ. ស. ១៨៨២ នៅភូមិបារាំង ពីដើមនៅក្បែរពន្ធនាគារធំ ភ្នំពេញ សង្កាត់លេខ ៣ ។

**សុគត** : ថ្ងៃអង្គារ ៩ កើត ខែពិសាខ ឆ្នាំរកា នព្វស័ក ព.ស. ២៥០០ ត្រូវនឹងថ្ងៃទី ៧ ឧសភា ១៩៥៧ វេលាម៉ោង ៥ និង ៤០ នាទី ក្នុងព្រះជន្មាយុ ៧៨ ឆ្នាំ ។

www.elibraryofcambodia.org



www.elibraryofcambodia.org

## ព្រះឧត្តមមុនី អ៊ុំ ស៊ូ

អតីត អធិបតីរងក្រុមជំនុំព្រះត្រៃបិដក

ព្រះអង្គគង់ជាអធិបតីរង នៃ ក្រុមជំនុំព្រះត្រៃបិដក ក្នុង គ. ស. ១៩២៩

**ប្រសូត :** នៅភូមិកន្សោមអក សង្កាត់កន្សោមអក ខេត្តព្រៃវែង នៅថ្ងៃពុធ ១៤ រោច ខែ ផល្គុន ឆ្នាំម្សាញ់ ត្រីស័ក ព. ស. ២៤២៤ ។

**សុគត :** ថ្ងៃសុក្រ ៥ កើត ខែទុតិយាសាឍ ឆ្នាំថោះ ឯកស័ក ព. ស. ២៤៨២ ត្រូវនឹង ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ១៩៣៩ ម៉ោង ២ កន្លះ ពាក់កណ្ដាលអាធ្រាត ព្រះជន្ម ៥៨ ឆ្នាំ ។

www.elibraryofcambodia.org



www.elibraryofcambodia.org

ព្រះមុនីកោសល សួរ ហាយ

សុវណ្ណញ្ញាណោភា អធិបតីរង

www.elibraryofcambodia.org

# កំណើតនៃក្រុមជំនុំព្រះត្រៃបិដក

ព្រះរាជប្រកាសលេខ ១០៦ ចុះថ្ងៃ ១៣ កើត ខែមិគសិរ ឆ្នាំម្សាញ់ ឯកស័ក ពុទ្ធសករាជ ២៤៧៣ ត្រូវនឹងថ្ងៃទី ១៤ ខែធ្នូ គ្រិស្តសករាជ ១៩២៩ បានតាំងបង្កើតឲ្យមានក្រុមជំនុំព្រះត្រៃបិដក មានអធិបតី ១ រូប និង អ្នកជំនុំច្រើនរូប ។ ក្រុមជំនុំនេះបានជួបជុំជានិច្ចក្នុងមន្ទីរព្រះរាជបណ្ណាល័យ ហើយបានប្រែព្រះត្រៃបិដកជាមុន ជូនបណ្ដើរ ៗ ទៅលោកកុង្ស៊ីយ៍សេនាបតី សម្រេចជាមួយនឹងលោក ឡឺរ៉េស៊ីដង់ស៊ុប៉េរីយើរ ជាអធិបតី ។

លុះកើតមានក្រុមពុទ្ធសាសនបណ្ឌិត្យ ដោយប្រកាសអារ៉េតេ លោកគូវែរណើរហ្សេណេរ៉ាល់ ឥណ្ឌូចិន ចុះថ្ងៃ ២៥ ខែមករា ឆ្នាំ១៩៣០ គឺថ្ងៃសៅរ៍ ១៣ រោច ខែបុស្ស ឆ្នាំម្សាញ់ឯកស័ក ពុទ្ធសករាជ ២៤៧៣ ក្រុមជំនុំព្រះត្រៃបិដកនេះក៏កាន់តែមានកម្លាំង និង ពន្លឺរស្មី បានចម្រើនថែមទៀត ។

លោកអ្នកផ្ដើមគំនិត ឲ្យប្រែព្រះត្រៃបិដក និង បោះពុម្ព តាមព្រះប្រកាសខាងលើនេះ គឺមាន :

– លោកហ្វែរណង់ត៍ [illegible] www.elibraryofcambodia.org [illegible] រ៉េពុយព្លិក បារាំង-សែស ក្នុងក្រុងកម្ពុជាធិបតី ។

– សម្ដេចចៅហ្វាវាំងវរះវៀងជ័យ អធិបតី **ជួន** សេនាបតីទី ១ សេនាបតីក្រសួងព្រះបរមរាជវាំង ព្រះឃ្លាំង និង រចនា ជាអ្នកពន្យល់ផ្ទាល់ ហើយព្រាងព្រះរាជប្រកាសជូនពិនិត្យសម្រេច ។

– សម្ដេចចក្រី កុញ្ញរាធិបតី **ម៉ុន** សេនាបតីក្រសួងយុទ្ធនាធិការ យោធាធិការ និង សិក្សាធិការ ។

– ក្រុមហ្លួង **ស៊ីសុវត្ថិ សុតានុវង្ស** ទីអគ្គមហាសេនា សេនាបតី ក្រសួងមហាផ្ទៃ និង ធម្មការ ។

- ឧកញ៉ាយោមរាជ **ជា** ភូសម្រេចរាជការក្រុមព្រះនគរបាល សេនាបតីក្រសួងយុត្តិធម៌ ។

- ក្រុមឃុន វិសុទ្ធិ ខត្តិយវង្ស **នរោត្តម សុរាម្រិត** ទីក្រឡាហោម សេនាតីបក្រសួងជើងទឹក ក្សេត្រាធិការ សិប្បិយការ និង ពាណិជ្ជការ ។

តមកខាងក្រោយ សម្ដេចចក្រី ម៉ុន មរណភាពទៅ ៖

- ក្រុមហ៊ុង ស៊ីសុវត្ថិ សុតានុវង្ស ឡើងទីជា ចក្រីកុញ្ញរាធិបតី ។

- ឧកញ៉ាមហាឥស្សរាធិបតី ម៉ែន ឡើងទីជា ឃោមរាជ ។

ឯក្រុមពុទ្ធសាសនបណ្ឌិត្យ ក្រុងកម្ពុជាធិបតី

ក្នុងសម័យនោះ គឺមាន ៖

- សម្ដេចក្រុមព្រះ វរចក្ររណរិទ្ធិ នរោត្ដម សុធារស អធិបតីក្រុមជំនុំសង្គហៈព្រះរាជវង្សានុវង្ស ។

- អ្នកស្រីក្រុំ ស៊ុយសាន តាទម៉ីឡែស ជាអគ្គលេខាធិការ ហើយជាអ្នករក្សាព្រះរាជបណ្ណាល័យកម្ពុជា ។

នៅពេលដែលក្រុមពុទ្ធសាសនបណ្ឌិត្យ បានផ្ទេរមកព្រះរាជរដ្ឋាភិបាលកាន់កាប់គឺតាំងពី គ.ស. ១៩៥០ មក ក្រសួងនេះក៏មាននាមថា“វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ” ឋិតនៅក្រោមឱវាទនៃក្រសួងធម្មការ ។

អស់លោកទទួលខុសត្រូវកាន់កាប់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ជាបន្តបន្ទាប់គ្នាមកនោះ គឺមាន ៖

www.elibraryofcambodia.org

- លោក យឿន ទីម ជាអគ្គលេខាធិការ ធ្វើការមកទល់ឆ្នាំ ១៩៦៤

- លោក ទ៉ុយ ម៉ុត ជាអគ្គលេខាធិការ ធ្វើការពីឆ្នាំ ១៩៦៤ ដល់ ១៩៦៥

- លោក ឈាង ហ៊័ប រាន គឺជាបច្ចុប្បន្ននាយកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ កាន់ការពីឆ្នាំ ១៩៦៥ មក(១) ។

- លោក លិម ឈាង ខិន បច្ចុប្បន្នអគ្គលេខាធិការ កាន់ការអមនាយកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ(២) ។

តមកខាងក្រោយទៀត ក៏មានព្រះរាជប្រកាសផ្សេង ៗ ថែមចំនួនអធិបតីរង ២ រូប និង ក្រុមជំនុំថ្មីជាច្រើនរូបតាមត្រូវការ ។

---

១ - តែងតាំងជានាយកទី ១ នៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ តាមព្រះរាជក្រឹត្យលេខ៦៦៣ ប.ក. ចុះថ្ងៃទី ២៨-១០-៦៥ ។ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនេះ បង្កើតឡើងតាមព្រះរាជក្រមលេខ ២១៦ ន. ស. ចុះថ្ងៃទី ២ កញ្ញា ១៩៥៣ ។

២- តែងតាំងជាអគ្គលេខាធិការ តាមព្រះរាជក្រឹត្យលេខ១៦៦ ប.ក. ចុះថ្ងៃទី ២១ មីនា១៩៦៦។

# ឋានន្តរ និង នាម

របស់

ក្រុមព្រះសង្ឃគិតិកាចារ្យ គឺ ក្រុមជំនុំប្រែព្រះត្រៃបិដក

## ក- ក្រុមជំនុំដែលមានពីឆ្នាំ ១៩២៩ មកទល់នឹងឆ្នាំ ១៩៤០ :

ក្រុមជំនុំមានព្រះសង្ឃជាអធិបតី ១, អធិបតីរង ២, ក្រុមជំនុំជាព្រះសង្ឃ ២៣, ជាឧបាសក ១១, ប្លុករួមទាំងអស់ត្រូវជា ៣៧ រូប គឺ :

១ - ព្រះសិរីសម្មតិវង្ស អែម វជិរប្បញ្ញោ ចាងហ្វាងសាលាបាលីជាន់ខ្ពស់ អធិបតី ។

២ - ព្រះឧត្តមមុនី អ៊ុំ ស៊ូ ធម្មវិនយរក្ខិតោ អធិបតីរង ។

៣ - ព្រះមហាព្រហ្មមុនី ឌេត អ៊ូ បិតវិរិយោ អធិបតីរង ។

www.elibraryofcambodia.org

ក្រុមជំនុំ

៤ - ព្រះសាសនសោភ័ណ ជួន ណាត ជោតញ្ញាណោ ចាងហ្វាងរង សាលាបាលីជាន់ខ្ពស់ ។

៥ - ព្រះវិសុទ្ធិវង្ស ហួត តាត វជិរប្បញ្ញោ អាចារ្យបង្រៀនសំស្ក្រឹត នៅសាលាបាលីជាន់ខ្ពស់ ។

៦ - ព្រះបាឡាត់សង្ឃវិជ្ជា មៀច មុនិត្ថេរោ

៧ - ព្រះមហា សោម ឈុន វិមលប្បញ្ញោ

៨ - ព្រះមហា សោម ឡុច សុធម្មលិខិតោ

៩ - ព្រះមហា សែស ចន្ទធម្មោ

១០ - ព្រះគ្រូញាណសំវរ ញាណ ឈឹន ជោតបញ្ញោ

១១ - ព្រះអាចារ្យ ចាប ពិន សុវណ្ណជោតោ

១២ - ព្រះមហា ឌិន ហួត នាគបណ្ឌិតោ

១៣ - ព្រះអាចារ្យ ម៉ែន សុខ ញាណសារោ អាចារ្យបង្រៀន
នៅសាលាបាលីជាន់ខ្ពស់ ។

១៤ - ព្រះអាចារ្យ ហែម ចៀវ ជោតញ្ញាណោ អាចារ្យបង្រៀន
នៅសាលាបាលីជាន់ខ្ពស់ ។

| | | | |
|---|---|---|---|
| ១៥ - | ព្រះអាចារ្យ | ឈឹម ស៊ុម | សទ្ធម្មប្បញ្ញោ |
| ១៦ - | ព្រះអាចារ្យ | សាំ ឌុំ | សោភណបណ្ឌិតោ |
| ១៧ - | ព្រះអាចារ្យ | សូរ ហាយ | សុវណ្ណញ្ញាណោ |
| ១៨ - | ព្រះអាចារ្យ | យូរ អ៊ុន | ឧត្តរញ្ញាណោ |
| ១៩ - | ព្រះអាចារ្យ | អ៊ុត ថា | វជិរញ្ញាណោ |
| ២០ - | ព្រះបាឡាត់ | អ៊ុយ ង៉ាខ | ខេមកោ |
| ២១ - | ព្រះគ្រូមុនីសុមេធា | ឡុង ថា | វេរកោ |
| ២២ - | ព្រះបាឡាត់ | គេត សោ | បិតសីលោ |
| ២៣ - | ព្រះអាចារ្យ | ម៉ុខ នាខ | ធម្មកោសលោ |
| ២៤ - | ព្រះអាចារ្យ | ម៉ៃ ង៉ាន់ | បណ្ឌិតវរោ |
| ២៥ - | ព្រះអាចារ្យ | អែន ម៉ច់ | វិនយសត្ថា |
| ២៦ - | ព្រះបាឡាត់ | ហែម ញឹម | សុន្ទរោ |
| ២៧ - | អ្នកមហា | ញ៉ុត ថែម | ឧបាសក |
| ២៨ - | អ្នកអាចារ្យ | ហុខ ឈា | - |
| ២៩ - | អ្នកអាចារ្យ | ខែត ហ៊ឹម | - |
| ៣០ - | អ្នកអាចារ្យ | ប៊ូ ប៉ូ | - |
| ៣១ - | អ្នកមហា | យូរ | - |
| ៣២ - | អ្នកអាចារ្យ | អ៊ុក សេន | - |
| ៣៣ - | អ្នកអាចារ្យ | ហ៊ី ហេខ | - |
| ៣៤ - | អ្នកអាចារ្យ | គិម អេន | - |

www.elibraryofcambodia.org

៣៥- អ្នកអាចារ្យ នួន ជួច ឧបាសក

៣៦- អ្នកអាចារ្យ សេក ឈុន -

៣៧- អ្នកអាចារ្យ អ៊ុច រស់ អាចារ្យបង្រៀននៅសាលាបាលីជាន់ខ្ពស់ ឧបាសក ។

## ខ- ក្រុមជំនុំដែលមានចាប់ពីឆ្នាំ ១៩៤០ មក :

ក្រុមជំនុំមានព្រះសង្ឃជាអធិបតី ១, អធិបតីរង ២, ក្រុមជំនុំជាព្រះសង្ឃ ២៧, ជាឧបាសក ១៣ បូករួមទាំងអស់ត្រូវជា ៤៣រូប គឺ :

១- ព្រះសិរីសម្មតិវង្ស ម៉ែម វជិរបញ្ញោ ចាងហ្វាងសាលាបាលីជាន់ខ្ពស់ អធិបតី ។

២- ព្រះមហាព្រហ្មមុនី ទេព អ៊ូ បិតវិរិយោ អធិបតីរង ។

www.elibraryofcambodia.org

៣- ព្រះសាក្យវង្ស ហួត តាត វជិរបញ្ញោ អាចារ្យបង្រៀនសំស្ក្រឹត នៅសាលាបាលីជាន់ខ្ពស់ អធិបតីរង ។

### ក្រុមជំនុំ :

៤- ព្រះពុទ្ធឃោសាចារ្យ ជួន ណាត ជោតញ្ញាណោ ចាងហ្វាងរងសាលាបាលីជាន់ខ្ពស់ ។

៥- ព្រះធម្មឃោសាចារ្យ មៀច មុនិត្ថេរោ

៦- ព្រះពុទ្ធវង្ស សោម ឈុន វិមលបញ្ញោ

៧- ព្រះមហា សែស ចន្ទធម្មោ

៨- ព្រះមហា សោម ឡុច សុធម្មលិខិតោ

៩- ព្រះគ្រូញាណសំវរ ញាណ ឈឹន ជោតបញ្ញោ

១០- ព្រះអាចារ្យ ទាប ពិន សុវណ្ណជោតោ

១១- ព្រះអាចារ្យ ឈឹម ស៊ុម សទ្ធម្មបញ្ញោ

| | | |
|---|---|---|
| ១២ - ព្រះអាចារ្យ | គាំ ឌុំ | សោភណបណ្ឌិតោ |
| ១៣ - ព្រះអាចារ្យ | ស្វូរ ហាយ | សុវណ្ណញ្ញាណោ |
| ១៤ - ព្រះអាចារ្យ | អ៊ុក ជា | វជិរញ្ញាណោ |
| ១៥ - ព្រះអាចារ្យ | យូ្វរ អ៊ុន | ឧត្តរញ្ញាណោ |
| ១៦ - ព្រះគ្រូមហាឧត្តុល | អ៊ុយ ង៉ែង | ខេមកោ |
| ១៧ - ព្រះគ្រូមង្គលមុនី | គេត សោ | បិតសីលោ |
| ១៨ - ព្រះបាឡាត់ញាណវីរិយ | ទ៉ាន់ សាឌុំ | |
| ១៩ - ព្រះបាឡាត់មហារាជធម្ម | ហ៊ី ជា | |
| ២០ - ព្រះអាចារ្យ | ម៉េង នាង | |
| ២១ - ព្រះបាឡាត់អរិយវិមល | នេត្រ | |
| ២២ - ព្រះអាចារ្យ | មៀច | |
| ២៣ - ព្រះអាចារ្យ | ម៉ួន | |
| ២៤ - ព្រះអាចារ្យ | ឡុង | |
| ២៥ - ព្រះអាចារ្យ | យូ្វរ ប៊ុន | |
| ២៦ - ព្រះអាចារ្យ | អែន ប៉ិច | វិនយសត្ថា |
| ២៧ - ព្រះអាចារ្យ | ញូង សៀង | |
| ២៨ - ព្រះអាចារ្យ | គីម គួរ | |
| ២៩ - ព្រះអាចារ្យ | ស៊ិន ហ៊ាន | |
| ៣០ - ព្រះអាចារ្យ | ពាង សុខ | |
| ៣១ - ព្រះអាចារ្យ | អៀង ថ្លាង | |
| ៣២ - ព្រះអាចារ្យ | ម៉ិញ ឈាត្រី | |
| ៣៣ - ព្រះធម្មបិដកវិជ្ជា | ង៉ែត ហ៊ឹម | |
| ៣៤ - អ្នកអាចារ្យ | ប៊ូ ប៉ូ | ឧបាសក |
| ៣៥ - អ្នកអាចារ្យ | ហុង ឈា | - |

www.elibraryofcambodia.org

| | | |
|---|---|---|
| ៣៦- អ្នកអាចារ្យ | ហ៊ី ហេង | ឧបាសក |
| ៣៧- អ្នកអាចារ្យ | ចាន់ ខាន់ | - |
| ៣៨- អ្នកអាចារ្យ | នួន ជួង | - |
| ៣៩- អ្នកមហា | ជា យូរ | - |
| ៤០ - អ្នកអាចារ្យ | ស្រី អ៊ូ | - |
| ៤១ - អ្នកអាចារ្យ | ឡុង ជា | - |
| ៤២- អ្នកអាចារ្យ | អ៊ុក ម៉ុត | - |
| ៤៣- អ្នកមហា | គិន ហួត | - |

គ. សមាជិកក្រុមជំនុំ ដែលបន្ថែមជាជំនួសសមាជិកទទួលអនិច្ចធម្មទៅៈ

| | |
|---|---|
| ១ - ព្រះមហាវីរិយបណ្ឌិតោ | ង៉ាំង ខាត់ |
| ២ - ព្រះបទុមវង្សា | គោត ផន |
| ៣ - ព្រះមហា | ចាយ គឹម សាន |
| ៤ - ព្រះមហា | ឈឹម នង |
| ៥ - ព្រះមហា | អ៊ុក អ៊ីន |
| ៦ - ព្រះមហា | មាស សុវណ្ណ |
| ៧ - ព្រះឥន្ទមុនី | សេង នាង |
| ៨ - លោក | ឈឹម ណាក |
| ៩ - លោក | មាឃ ស៊ុន |
| ១០ - លោក | អ៊ុម តន |
| ១១ - លោក | គុយ សូត្រ |
| ១២ - លោក | មាស យុត្ត |
| ១៣- លោក | គី គឹម ស៊ីង |
| ១៤ - លោក | អ៊ុក សាន |
| ១៥ - លោក | ទ្រាក់ ឈូក |

www.elibraryofcambodia.org

១៦ - លោក ស្មៀន ឱន

១៧ - លោក ឱក ប៊ិន

១៨ - លោក យ៉ាន់ អ៊ុន ហៅ អន អ៊ុយ

១៩ - លោក អ៊ុំ គយ

២០ - លោក ត្រួច គុម

២១ - ព្រះធម្មវិសុទ្ធិវង្ស គង់ គូ

២២ - លោក សរ សឿន

## ឃ- ក្រុមជំនុំដែលនៅធ្វើការជាប់សព្វថ្ងៃ :

ក្រុមជំនុំមានព្រះសង្ឃជាអធិបតី ១ អធិបតីរង ១ ក្រុមជំនុំជាព្រះសង្ឃ ១១ រូប, ជាឧបាសក ១, ឬករួមទាំងអស់ត្រូវជា ១៣ រូប គឺ :

១- សម្តេចព្រះពោធិវង្ស ហួត តាត វជិរប្បញ្ញោ អគ្គាធិការពុទ្ធិកសិក្សា កម្ពុជរដ្ឋ និង ជាសកលវិទ្យាធិការ នៃ ពុទ្ធិកសកលវិទ្យាល័យ ព្រះសីហនុរាជ អធិបតី ។

www.elibraryofcambodia.org

២ - ព្រះមុនីកោសល សួរ ហាយ សុវណ្ណញ្ញាណោ អធិបតីរង ។

៣- ព្រះពុទ្ធាចារ្យ ហ៊ី ជា

៤ - ព្រះសាសនមុនី គឹម គួរ

៥ - ព្រះវិសុទ្ធិវង្ស ម៉ៅ ខាន់

៦ - ព្រះសិរីសម្មតិវង្ស ធន់ ស៊ីន

៧ - ព្រះញាណវង្ស អ៊ុម ស៊ុម

៨ - ព្រះធម្មវរោត្តម ជា សុខ

៩ - ព្រះញាណសំវរ ហេង លាង ហោ

១០- ព្រះមហា ប៉ែន សេង អាន

១១- ព្រះមហា ទ៉ាន់ ឌីន

១២- ព្រះមហា ប៊ុក សុន

១៣- លោក ផល និត

នៅពេលដែលបោះពុម្ពចប់សៀវភៅភាគទី ១ មួយភាគជាដំបូង គឺត្រូវនឹងវេលាដែលលោក **ម៉ូល - រ៉េណូធ៍** ជាអធិបតីក្នុងរាជការធំបារាំងសែស ក្រសួងប្រទេសរាជ្យ អញ្ជើញមកទស្សនាការប្រទេសឥណ្ឌូចិន ។ ដោយបានជ្រាបនូវកិច្ចការផ្សាយនូវព្រះពុទ្ធសាសនានេះ លោក **ម៉ូល - រ៉េណូធ៍** នេះ ក៏បានសុំឲ្យរៀបធ្វើពិធីសម្ពោធសៀវភៅព្រះវិន័យបិដកជាបឋម ដែលបោះពុម្ពបានមួយក្បាលហើយនោះ ឆ្លងនៅថ្ងៃព្រហស្បតិ ១១ កើត ខែអស្សុជ ឆ្នាំមមែត្រីស័ក ពុទ្ធសករាជ ២៤៧៤ ត្រូវនឹងថ្ងៃទី ២២ ខែតុលា គ្រិស្តសករាជ ១៩៣១ វេលាម៉ោង ៥ រសៀល ក្រោមព្រះរាជាធិបតីភាពនៃព្រះករុណាជាអម្ចាស់ជីវិតព្រះបាទសម្តេចព្រះ **ស៊ីសុវត្ថិ មុនីវង្ស** ។ លោក **ម៉ូល - រ៉េណូធ៍** មានសេចក្តីជ្រះថ្លា បានចូលបច្ច័យ ១ ពាន់រៀល ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ក្នុងការបោះពុម្ពព្រះត្រៃបិដកនេះ ។ ព្រះករុណាជាអម្ចាស់ជីវិត ដ៏ទ្រង់នូវព្រះគុណធម៌ មហាប្រសើរ ក៏ទ្រង់បានចូលរូបិយវត្ថុ ព្រះរាជទ្រព្យជាច្រើន ព្រមទាំងឧបាសកឧបាសិកាទាំងឡាយជាអនេកក្នុងព្រះនគរ ក៏បានចូលប្រាក់យ៉ាងច្រើន ក្នុងការបោះពុម្ពព្រះត្រៃបិដកនេះដែរ ។

www.elibraryofcambodia.org

កិច្ចចាត់ចែងបោះពុម្ពផ្សាយព្រះត្រៃបិដកពីដើមទីមក គឺបិតនៅក្នុងបន្ទុកបច្ច័យរបស់អស់លោក-អ្នកជាពុទ្ធបរិស័ទមកចុះនាមជាវ រួមជាមួយថវិការបស់រាជការអាណាព្យាបាល ។ ចាប់តាំងពីឆ្នាំ ១៩៥០ មកទល់បច្ចុប្បន្ននេះ ថវិកាជាតិទទួលបន្ទុកនូវការបោះពុម្ពផ្សាយរហូតដល់ចប់ទាំង ១១០ ភាគនៃព្រះត្រៃបិដកនេះ ដើម្បីជាវជូនតម្លៃយ៉ាងទាបបំផុតចំពោះពុទ្ធបរិស័ទទូទៅ ។ បើគិតតាំងពីផ្តើមផ្ទៀងផ្ទាត់ប្រែព្រះត្រៃបិដកក្នុង គ.ស. ១៩២៩ មកដល់ ១៩៦៨ ទើបចប់ បានបោះពុម្ពហើយស្រេចទាំង ១១០ ភាគ គឺអស់រយៈកាល ៣៩ ឆ្នាំ គត់ ។

## អំពីការប្រែ និង រៀបសេចក្តីនៃព្រះត្រៃបិដក

ចាប់តាំងពីវេលាដែលផ្តើមធ្វើការប្រែព្រះត្រៃបិដក ដរាបដល់សព្វថ្ងៃនេះ យើង

រាល់គ្នាតែងមានសេចក្ដីរិតក្កអំពីការប្រែ និង រៀបសេចក្ដីនោះច្រើនប្រការពេក ឥត មានភ្លេចភ្លាំងឡើយ ដូចអធិប្បាយនិងរៀបរាប់តទៅនេះ ។

ក៏ទំនងប្រយោគនិងរបៀបសេចក្ដីក្នុងគម្ពីរព្រះត្រៃបិដក ដែលបានប្រែនិងរៀបចំធ្វើស្រេចមកហើយនោះ មានសេចក្ដីសាំដដែល ។ ច្រើនកន្លែងណាស់ នាំឲ្យអស់លោកអ្នកមើល អ្នកស្ដាប់គ្រប់គ្នាធុញទ្រាន់ គួរឲ្យកើតសេចក្ដីសង្ស័យថា « ហេតុដូចម្ដេច » បានជាអស់លោកក្រុមជំនុំព្រះត្រៃបិដក ប្រែនិងរៀបរៀងសេចក្ដីឲ្យសាំដដែល ។ ដូច្នោះ ? ចុះសៀវភៅឯទៀត ។ ដែលជាសៀវភៅរាយរងបន្ទាប់បន្សំមានសៀវភៅគិហិបដិបត្តិ ជាតិមោក្ខសង្ខេប និង សិង្គាលោវាទសូត្រជាដើម ក៏សុទ្ធតែជាសៀវភៅប្រែចេញចាកភាសាបាលីដូចគ្នាដែរ ម្ដេចក៏ចេះធ្វើសេចក្ដីឲ្យស្រួលបួល ងាយមើល ងាយស្ដាប់បាន? សៀវភៅព្រះត្រៃបិដកនេះ ជាគម្ពីរដើមជាឫសគល់នៃសៀវភៅឯទៀត។ គួរតែប្រែនិងរៀបរៀងសេចក្ដីឲ្យងាយមើល ងាយស្ដាប់ជាងគេ ទើបសម ចុះហេតុអ្វីក៏បានជាប្រែនិងរៀបសេចក្ដីឲ្យរឹងរឹតតែលំបាកមើល លំបាកស្ដាប់ជាងសៀវភៅឯទៀត ។ ទៅវិញ ?

www.elibraryofcambodia.org

យើងសូមជូនដំណឹងដល់អស់លោក អ្នកមើល អ្នកស្ដាប់ព្រះត្រៃបិដកសម្រាយសូមជ្រាប ត្បិតយើងទាំងអស់គ្នាមិនមែនចូលចិត្តចង់ប្រែនិងរៀបរៀងសេចក្ដីឲ្យសាំដូច្នោះទេ, ប្រសិនបើកាត់បាលីខ្លះសម្រាយខ្លះ ត្រង់កន្លែងណាដែលដូច ។ គ្នា ឲ្យស្រួលមើល ស្រួលស្ដាប់ទៅ ក៏បាន ប៉ុន្តែមុនដែលនឹងប្រែនោះ យើងបានពិនិត្យមើលរបៀបនិងលំនាំការរបស់លោកអ្នកប្រាជ្ញធំៗជាអ្នកកាន់ព្រះពុទ្ធសាសនាមាំមួនអំពីជាន់មុន ។ ដែលលោកបានប្រជុំធ្វើការសង្គាយនារៀបរៀងផ្ទៀងផ្ទាត់ព្រះត្រៃបិដកមកឃើញថា កាលដែលព្រះបរមគ្រូទើបនឹងបរិនិព្វានទៅថ្មី ។ ព្រះអរហន្ត ៥០០ អង្គមានព្រះមហាកស្សបត្ថេរជាប្រធាន បានប្រជុំគ្នា ធ្វើបឋមសង្គាយនារួបរួមធម៌វិន័យដែលព្រះបរមសាស្ដាទ្រង់សម្ដែងទាំងប៉ុន្មាន ទុកជាច្បាប់សម្រាប់រៀនទន្ទេញឲ្យត្រូវគ្នាជាបែបមួយ, ដល់មកសង្គាយនាគ្រាក្រោយ ។ ក៏តម្រូវតាមរបៀបមុន ។ នោះដែរ ឥតមានកែប្រែឲ្យលើសខ្វះឡើយ ។

ន័យមួយទៀត កាលដែលព្រះសម្មាសម្ពុទ្ធបរមគ្រូជិតនឹងបរិនិព្វាន ទ្រង់បានត្រាស់ផ្ដាំនឹងព្រះអានន្ទថា «ម្នាលអានន្ទ កាលបើតថាគតបរិនិព្វានទៅហើយ វេលាដែលសង្ឃនឹងប្រជុំគ្នាធ្វើសង្គាយនាធម៌វិន័យនោះ, បើសង្ឃត្រូវការដកខុទ្ទានុខុទ្ទកសិក្ខាបទ គឺសិក្ខាបទតូច ៗ ជាលំដាប់បន្ទាប់បន្សំ ក៏ចូរដកចេញខ្លះចុះ» ។ លុះដល់ការគសង្ឃប្រជុំគ្នាធ្វើ ក៏យល់ព្រមគ្នាថា « ខុទ្ទានុខុទ្ទកសិក្ខាបទទាំងនោះមិនគួរដកចោលទេ, ទោះបីព្រះបរមគ្រូទ្រង់អនុញ្ញាតឲ្យដកចេញមែនក៏ដោយ, តែការនេះស្រេចនឹងក្រុមជំនុំសង្ឃ ព្រះបរមសាស្ដាទ្រង់មិនមែនបង្ខំថា ត្រូវតែដកចោល ខានមិនបានទេ, ហេតុនោះសង្ឃនឹងដកក៏បាន នឹងទុកក៏បាន តែកាលបើដកចេញទៅមុខជានឹងមានពាក្យតរហានិន្ទាថា ពួកសាវ័ករបស់ព្រះសមណគោតម គ្រាន់តែគ្រូចូលនិព្វានទៅមិនទាន់បានយូរប៉ុន្មាន ក៏បបួលគ្នាដករុះរើច្បាប់ទម្លាប់របស់គ្រូចោល ហេតុដូច្នោះ សិក្ខាបទបន្ទាប់បន្សំនោះគួរតែទុកកុំកែប្រែ កុំឲ្យព្រះពុទ្ធសាសនាទៅជាធ្មមការលើក ព្រោះថាសិក្ខាបទដែលព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យសង្ឃដកចេញនោះមិនមែនជាការខុសទេ គ្រាន់តែជាសិក្ខាបទមានចំនួនច្រើនប៉ុណ្ណោះទេតើ » ។

www.elibraryofcambodia.org

ដោយហេតុពោលមកហើយនេះ បានជាយើងយល់ឃើញថា ទំនងប្រយោគនិងរបៀបសេចក្ដី ក្នុងព្រះត្រៃបិដកទាំងបាលីនិងសម្រាយនេះ ពិតជាមានសេចក្ដីសាំដដែល ៗ ច្រើនលើកច្រើនដងមែន ប៉ុន្តែមិនមែនជាការខុសទេ, គួរតែទុកឲ្យនៅតាមទំនងប្រយោគនិងរបៀបសេចក្ដីដើម ដែលអ្នកប្រាជ្ញជាន់មុន ៗ លោកសង្គាយនានោះ, ព្រោះព្រះត្រៃបិដកនេះជាគោលដើម ជាគម្ពីរចាស់ជាងគម្ពីរទាំងពួងដែលកើតឡើងក្នុងព្រះពុទ្ធសាសនា ។

ម្យ៉ាងទៀត គម្ពីរព្រះត្រៃបិដកនេះ ជាគម្ពីរមានអាយុរាសីវែងឆ្ងាយចំនួន ២៤៧០ ប្លាយឆ្នាំមកហើយ, មិនដែលឮថាអ្នកប្រាជ្ញជាន់ណា ៗ ហ៊ានបំប្រួញសេចក្ដីឲ្យខ្លីចុះ ឬបំពេញឲ្យវែងឡើងខុសចាកច្បាប់ដើមនោះឡើយ ។ កាលពុទ្ធសករាជកន្លងទៅបាន ៩៥៦ ឆ្នាំ មានសេចក្ដីតំណាលថា ព្រះពុទ្ធឃោសាចារ្យនៅមជ្ឈិមប្រទេស លោកទៅចម្លងព្រះត្រៃបិដកនៅឯលង្កាទ្វីប យកមកផ្សាយក្នុងជម្ពូទ្វីប គឺ

ប្រទេសឥណ្ឌា នោះលោកក៏មិនហ៊ានបន្ថយឬបន្ថែមសេចក្ដីក្នុងព្រះត្រៃបិដកនេះទេ គ្រាន់តែចម្លងតាមច្បាប់ដើមប៉ុណ្ណោះ លុះចម្លងបិដកទាំង ៣ បានចប់សព្វគ្រប់ហើយ ទើបលោកខំព្យាយាមប្រែអដ្ឋកថាអំពីសីហឡភាសា (សម្ពិអ្នកលង្កា-ទ្វីប) មកជាមគធភាសាដោយសព្វគ្រប់ ហើយលោកបានជ្រើសរើសស្រង់យកធម៌វិន័យក្នុងព្រះត្រៃបិដកនោះមករៀបរៀងសេចក្ដី ធ្វើជាបករណ៍វិសេសមួយដោយឡែកឲ្យឈ្មោះថា « **វិសុទ្ធិមគ្គ** » សម្ដែងអំពីសីល សមាធិ បញ្ញា មានទំនងប្រយោគនិងរបៀបសេចក្ដីខ្ពង់ល្អ ស្រួលមើល ស្រួលស្ដាប់ ទោះបីអាថ៌ធម៌ក្នុងគម្ពីរនោះមានសេចក្ដីចង្អៀតជ្រាលជ្រៅដូចម្ដេចក្ដី ក៏គង់មិនផ្លូនផដែល ៗ ឡើយ, សូម្បីគម្ពីរឯទៀតដែលលោកបានតែង បានរៀបរៀងក្នុងគ្រានោះទាំងប៉ុន្មាន ដូចអដ្ឋកថាធម្មបទជាដើម ក៏មានទំនង ប្រយោគនិងរបៀបសេចក្ដីមិនសាំផដែល ៗ ដែរ ។ ឯហេតុដែលជាទំនងនាំឲ្យលោកមានព្យាយាមខំប្រឹងទ្រាំរៀបចំតែងធ្វើជាគម្ពីរឯទៀត ជាគ្រឿងបំភ្លឺសេចក្ដីក្នុងព្រះត្រៃបិដកនោះ មិនមែនព្រោះហេតុអ្វីទេ, ព្រោះតែលោកមិនហ៊ានរុះរើរបៀបសេចក្ដីដែលមាននៅក្នុងព្រះត្រៃបិដកជាគោលដើមនោះឯង ទើបលោកទុកជាច្បាប់ចាស់ តាមកាល តាមសម័យនៃអ្នកប្រាជ្ញជាន់មុន ៗ ដែលលោកខំធ្វើជាគម្ពីរផ្សេង ៗ មានវិសុទ្ធិមគ្គជាដើម សម្រាប់រៀន សម្រាប់មើលនោះ ក៏មានទំនងប្រហែលគ្នានឹងសម័យឥឡូវនេះ ដែលយើងនាំគ្នាជ្រើសរើសយកធម៌វិន័យក្នុងបាលីព្រះត្រៃបិដកខ្លះ, ក្នុងអដ្ឋកថាដីកាយោជនារបស់បិដកទាំងនោះខ្លះ មករៀបរៀងធ្វើជាសៀវភៅតូច ៗ សម្រាប់ចែកគ្នារៀនសូត្រសព្វថ្ងៃនេះដែរ ។

## អំពីរបៀបដែលរៀបជាសៀវភៅព្រះត្រៃបិដក

ព្រះត្រៃបិដកមួយចប់ បើចែកជាពួកមាន ៣ ពួក គឺ វិន័យបិដក ១ ពួក, សុត្តន្តបិដក ១ ពួក, អភិធម្មបិដក ១ ពួក, ចែកចេញជាគម្ពីរ មានឈ្មោះ ១៧ ចែកចេញជាសៀវភៅដែលយើងប្រែ ហើយបោះពុម្ពក្នុងសម័យនេះ ១១០ ភាគគត់នៃសៀវភៅ ។

www.elibraryofcambodia.org

វិន័យបិដកមាន ៥ ឈ្មោះ គឺ មហាវិភង្គ ឬ ភិក្ខុវិភង្គ ១ ភិក្ខុនីវិភង្គ ១ មហាវគ្គ ១ ចុល្លវគ្គ ១ បរិវារៈ ១, ទាំង ៥ ឈ្មោះនេះ ចែកទៅជាសៀវភៅបោះពុម្ពមាន ១៣ ភាគ ។

សុត្តន្តបិដកមាន ៥ ឈ្មោះគឺ ទីឃនិកាយ ១ មជ្ឈិមនិកាយ ១ សំយុត្តនិកាយ ១ អង្គុត្តរនិកាយ ១ ខុទ្ទកនិកាយ ១, ទាំង ៥ ឈ្មោះនេះចែកជាសៀវភៅបោះពុម្ព មាន ៦៣ ភាគ ។

អភិធម្មបិដកមាន ៧ ឈ្មោះគឺ ធម្មសង្គណី ១ វិភង្គ ១ ធាតុកថា ១ បុគ្គលបញ្ញត្តិ ១ កថាវត្ថុ ១ យមកៈ ១ មហាបដ្ឋាន ឬ បដ្ឋាន ១, ទាំង ៧ ឈ្មោះនេះ ចែកទៅជាសៀវភៅបោះពុម្ពមាន ៣៤ ភាគ ។ បូករួមសៀវភៅវិន័យបិដក ១៣ ភាគ សុត្តន្តបិដក ៦៣ ភាគ អភិធម្មបិដក ៣៤ ភាគ ត្រូវជា ១១០ ភាគ ។

ការបោះពុម្ពនោះ បានចាត់ការបោះវិន័យបិដកជាមុនដំបូង, បានបោះវិន័យបិដកនោះរួចហើយ ក្នុងរវាងពុទ្ធសករាជ ២៤៧៩ គ្រិស្តសករាជ ១៩៣៦ ។

www.elibraryofcambodia.org

## អំពីប្រយោជន៍នៃការប្រែព្រះត្រៃបិដក

អ្នកកាន់ព្រះពុទ្ធសាសនា គួរតែលើកចិត្តឲ្យឡើងមកកាន់សេចក្ដីជ្រះថ្លា ក្នុងការប្រែព្រះត្រៃបិដក និងរៀបរៀងសេចក្ដីជាសម្រាយនោះឲ្យយ៉ាងច្រើន ព្រោះការផ្ទៀងផ្ទាត់បាលីឲ្យត្រឹមត្រូវ ហើយប្រែចេញមកជាសម្រាយបោះពុម្ពនេះ ជាកិច្ចមានប្រយោជន៍ច្រើនប្រការណាស់ មានប្រយោជន៍ដូច្នេះ គឺ :

១- សេចក្ដីសម្រាយងាយមើល ងាយស្ដាប់ជាងបាលី ព្រោះលោកអ្នកប្រែបានរិះគិតរកទំនងសេចក្ដីឲ្យស្រួលមើល ស្រួលស្ដាប់រួចជាស្រេច ។

២- ធ្វើដំណឹងពុទ្ធសាសនា តាំងអំពីដើមដរាបដល់ចុង គឺតាំងអំពីព្រះសម្មាសម្ពុទ្ធមិនទាន់ចូលបរិនិព្វាន រហូតមកដល់ឥឡូវនេះ ឲ្យរាក់ ឲ្យងាយឡើង មិនកំបាំងបាត់ជ្រៅពេក ។

៣- បើពុទ្ធបរិស័ទមានបំណងនឹងរៀន នឹងប្រតិបត្តិតាម សីល សមាធិ បញ្ញា ក៏មានបរិបូណ៌ក្នុងព្រះត្រៃបិដកនោះសព្វគ្រប់ ។

៤- ព្រះត្រៃបិដកនេះបានអណ្ដែតត្រសែតឬប្រសូត្រចេញចាកផ្ទៃនៃមាតា គឺព្រះសម្មាសម្ពុទ្ធជាបរមសាស្តានៃពុទ្ធមាមិកជននោះជ្រះស្រឡះហើយ ឲ្យឃើញប្រាកដដល់ភ្នែកយើងគ្រប់គ្នា ដោយមិនលំបាកងាករកប៉ុន្មានឡើយ ។

៥- យើងរាល់គ្នាដែលបានព្រះត្រៃបិដកបោះពុម្ព បាលីម្ខាង សម្រាយម្ខាងនេះ ប្រៀបដូចជាបានប្រទីបឬគោមគំពីរផ្លូវតាំងនៅអមផ្លូវទាំងពីរខាង ដែលជាផ្លូវដើរទៅរកទីក្សេមក្សាន្ត ជាផ្លូវដែលអ្នកឥតសំណាងមិនត្រូវការបានចូលដើរជ្រៀតជ្រៀតទៅជាមួយផងបានឡើយ ។

៦- ប្រទេសយើងជាប្រទេសមានសំណាងខ្ពស់ មានលាភពិណាស់ ដែលបានព្រះត្រៃបិដកមួយចប់ ទុកដូចជាមាន ២ ចប់ ព្រោះបោះពុម្ពបាលីម្ខាង សម្រាយម្ខាងនេះ ហាក់ដូចជាបានថ្នាំសព្វ ២ បំពង់កែវ ថ្នាំសព្វនេះនឹងអាចរម្ងាប់រោគច្រើនយ៉ាង មានរោគគ្រុនក្ដៅក្រហាយ គឺសេចក្ដីវិវាទទាស់ទែងខ្វែងគំនិតគ្នាជាដើម និងសេចក្ដីសង្ស័យមិនដាច់ស្រេចជាយូរមកហើយនោះ ឲ្យបានសះស្បើយជាប្រាកដ ។

ព្រះត្រៃបិដកនេះ មិនមែនមានតែក្នុងប្រទេសយើងទេ ប្រទេសឯទៀត ៗ ដូចប្រទេស សៀម ភូមា លង្កា និង អឺរ៉ុបជាដើមក៏មានដែរ, អ្នកប្រទេសទាំងនោះគេក៏បានផ្ទៀងផ្ទាត់បោះពុម្ពហើយ ប៉ុន្តែគេបោះពុម្ពតែជាភាសាបាលីសុទ្ធ មិនទាន់បានប្រែជាសម្រាយឲ្យចប់សព្វគ្រប់ ដូចប្រទេសយើងដែលបានប្រែចប់ បានបោះពុម្ពស្រេចហើយនេះទេ ។

ឯការបោះពុម្ពជាភាសាបាលីសុទ្ធនោះ ឃើញនៅមានភ្លាំងភ្លាត់ខ្លះ ដោយអន្ទើៗព្រោះមិនទាន់បានរិះរកសេចក្ដីឲ្យមាំមួននៅឡើយ គ្រាន់តែឃើញថាតួបាលីត្រឹមត្រូវតាមរបៀបវេយ្យាករណ៍ឬគាថា ហើយក៏បោះពុម្ពទៅ ដូចយ៉ាងព្រះត្រៃបិដកអក្សរសៀម, អក្សរភូមា និង អក្សរអឺរ៉ុប ក្នុងវិនយបិដកបរិវារៈត្រង់គាថាសង្គណិកៈ (១)

(១) វិនយបិដក បរិវារៈ ទុតិយភាគ ទី ១៣ ទំព័រ ១២២ ។

www.elibraryofcambodia.org

ដែលសម្តែងអំពីចំនួនសិក្ខាបទថា សិក្ខាបទរបស់ភិក្ខុ និង ភិក្ខុនីដែលព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថីមានចំនួន ២៩៤ តែយើងបានរាប់មើលត្រង់គាថាដែលជាបញ្ជីរាយឈ្មោះប្រាប់ចំនួន ឃើញតែ ២៨៤, មើលក្នុងបញ្ជីបូករួម ឃើញថា ២៩៤ មិនត្រូវគ្នា, គឺក្នុងបញ្ជីរាយឈ្មោះថា បារាជិក ៤ សង្ឃាទិសេស ១៦ អនិយតៈ ២ និស្សគ្គិយៈ ២៤ ខុទ្ទកសិក្ខាបទ ១៥៦ បាដិទេសនីយៈ ១០ សេក្ខិយៈ ៧២ « ជា ២៨៤ » បាត់ ១០ សិក្ខាបទ, ប៉ុន្តែចំណែកខាងគម្ពីរសិក្ខាវិតខ្មែរយើងច្បាប់ខ្លះថានិស្សគ្គិយៈ ២៤ ដូចគ្នានឹងបិដកប្រទេសឯទៀតដែរ, ច្បាប់ខ្លះថានិស្សគ្គិយៈ ៣៤ ។ កាលបើដូច្នេះ យើងក៏មានសេចក្តីត្រិះរិះថា បញ្ជីរាយឈ្មោះហើយនិងបញ្ជីបូករួម តើខាងណាត្រូវខាងណាខុស ? ដើម្បីឲ្យប្រាកដក្នុងសេចក្តីនេះ យើងបានសាត្រឡប់ទៅរើមើលក្នុងវិនយបិដក មហាវិភង្គ និង ភិក្ខុនីវិភង្គខាងដើម តាំងអំពីបឋមបារាជិក រៀងរហូតដល់ សេក្ខិយៈ ជាទីបំផុត ក៏ឃើញថាសិក្ខាបទដែលទ្រង់បញ្ញត្តក្នុង [illegible] www.elibraryofcambodia.org ដូច្នេះ គឺ បារាជិក ៤ សង្ឃាទិសេស ១៦ អនិយតៈ ២ និស្សគ្គិយៈ ៣៤ ខុទ្ទកសិក្ខាបទ ១៥៦ បាដិទេសនិយៈ ១០ សេក្ខិយៈ ៧២ «រួមជា ២៩៤» ត្រូវតាមបញ្ជីដែលលោកបូករួម ។ យើងក៏សម្រេចសេចក្តីថា ព្រះត្រៃបិដកអក្សរសៀម អក្សរភូមា អក្សរអឺរ៉ុប និង ច្បាប់សិក្ខាវិតអក្សរខ្មែរយើងខ្លះ ដែលរាយឈ្មោះប្រាប់ចំនួនត្រង់និស្សគ្គិយៈថា ២៤ នោះខុស លុះតែថា ៣៤ ដូច្នេះវិញ ទើបត្រូវ តាមន័យក្នុងមហាវិភង្គ និង ភិក្ខុនីវិភង្គនោះដោយពិត ។ យើងបានដាក់ក្នុងបញ្ជីរាយឈ្មោះនោះថា «និស្សគ្គិយៈ ៣៤» តម្រូវតាមមហាវិភង្គ ភិក្ខុនីវិភង្គ និង ច្បាប់សិក្ខាវិតអក្សរខ្មែរនោះដោយត្រឹមត្រូវហើយ ។

ការដែលរិះរកឃើញខុសត្រូវយ៉ាងនេះ ក៏មកអំពីបានប្រែហើយផ្ទៀងផ្ទាត់នោះឯងជាបច្ច័យ ។ ព្រោះហេតុនោះបានជាឃើញថា ការប្រែព្រះត្រៃបិដកមកជាសម្រាយនេះ ជាការមានប្រយោជន៍ដ៏ខ្ពស់បំផុត ឥតមានការភ័ន្តច្រឡំដូចដែលគ្រាន់តែអានបាលីត្រួស ៗ ឥតគិត ឥតរាប់នោះឡើយ ។

# ឧប្បត្តិហេតុ
## នៃការកសាងព្រះត្រៃបិដក

ហេតុដែលជាទំនងនាំឲ្យកើតព្រះត្រៃបិដក បោះពុម្ពឡើងបាននោះ ព្រោះអាស្រ័យនូវគុណសម្បត្តិច្រើនយ៉ាង គឺព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ប្រកបដោយព្រះរាជសទ្ធាក្នុងព្រះពុទ្ធសាសនា ទ្រង់មានព្រះចិន្តាប្រាថ្នានឹងឲ្យអ្នកកាន់ព្រះពុទ្ធសាសនា រៀនសូត្រឲ្យបានចេះដឹងឡើង ហើយប្រព្រឹត្តតាមសេចក្ដីចេះដឹងនោះផង, ព្រមទាំងរាជការប្រតិកតូរ៉ាត៍ និង អស់លោកកុង្ស៊ីយ៍សេនាបតី លោកក៏មានសេចក្ដីសង្គ្រោះដល់ពួកមហាជន ក្នុងប្រទេសកម្ពុជានេះ ឲ្យមានគម្ពីរក្បួនច្បាប់យ៉ាងត្រឹមត្រូវជាគោលចារីកផង, អាស្រ័យនឹងប្រាក់ចំណូលរបស់មហាជនដែលមានសេចក្ដីជ្រះថ្លា ចូលជាវព្រះត្រៃបិដកនោះ មានចំនួនច្រើនចប់ផង, មិនតែប៉ុណ្ណោះ ក្នុងសម័យនេះមិនទាន់មានមន្ទីរដែលជាទីសម្រាប់ជួយឧបត្ថម្ភការបោះពុម្ពព្រះត្រៃបិដកនោះជាច្រើនកន្លែង គឺ សាលាបាលីជាន់ខ្ពស់ដែលជាកន្លែងសម្រាប់បង្រៀនប្រែភាសាបាលី, មន្ទីរព្រះរាជបណ្ណាល័យកម្ពុជា ដែលជាកន្លែងសម្រាប់តម្កល់គម្ពីរព្រះត្រៃបិដក ជាភាសាបាលីច្រើនចប់ និងក្បួនច្បាប់ឯទៀត ៗ ជាច្រើន វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ដែលសម្រាប់ចាត់ចែងកិច្ចការខាងព្រះពុទ្ធសាសនា និងសម្រាប់ផ្សាយព្រះពុទ្ធសាសនា ក្នុងកម្ពុជរដ្ឋយើងនេះនិងទៅប្រទេសឯទៀត ដែលនៅក្នុងប្រទេសឥណ្ឌូចិនបារាំងសែស ។

www.elibraryofcambodia.org

ព្រះត្រៃបិដកនេះ ចាប់ផ្ដើមធ្វើតាំងពីឆ្នាំមមីត្រីស័ក ពុទ្ធសករាជ ២៤៧២ ត្រូវនឹងគ្រិស្តសករាជ ១៩៣០ ។

ឯព្រះត្រៃបិដកដែលបោះពុម្ពក្នុងសម័យនេះ មានចំនួន ១១០ ភាគ ជាសៀវភៅ ក្នុងសៀវភៅនីមួយ ៗ មានទាំងបាលី ទាំងសម្រាយ, បាលីនៅទំព័រខាងឆ្វេង សម្រាយនៅទំព័រខាងស្ដាំ គ្រប់សៀវភៅទាំងអស់, សៀវភៅទាំងនោះ បោះពុម្ពច្រើនពាន់ចប់ តាមចំនួនអ្នកដែលទទួលជាវយក ព្រមទាំងទុកបម្រុងឲ្យអ្នកត្រូវការ

ជាវត ៗ ទៅទៀត ត្រាតែមានព្រះត្រៃបិដកមួយចប់ៗ រាល់វត្តក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូលផង ។

បណ្តាសៀវភៅព្រះត្រៃបិដកចំនួន ១១០ ភាគនោះ ចែកជាព្រះវិន័យ ១៣ ភាគ ជាព្រះសូត្រ ៦៣ ភាគ, ជាព្រះអភិធម្ម ៣៤ ភាគ ។

តាំងអំពីព្រះបរមគ្រូទ្រង់ចូលបរិនិព្វានទៅ រហូតមកដល់សព្វថ្ងៃនេះ ក្នុងគម្ពីរដីកា ឬក្បួនច្បាប់ ពង្សាវតារណា ៗ ក៏មិនដែលឮថា មានគេប្រែព្រះត្រៃបិដកចប់សព្វគ្រប់យ៉ាងនេះឡើយ ។

ដែលមានតំណាលមកក្នុងគម្ពីរបាលី មានគម្ពីរមហាវង្សជាដើមនោះថា តាំងអំពីពុទ្ធសករាជទី ១ គឺឆ្នាំដែលព្រះបរមសាស្តាចូលបរិនិព្វានទៅថ្មីៗនោះ ព្រះអរហន្តចំនួន ៥០០ អង្គ មានព្រះមហាកស្សបជាដើម លោកប្រជុំគ្នាធ្វើសង្គាយនាជាដំបូង ផ្ទៀងផ្ទាត់ព្រះពុទ្ធវចនៈឲ្យតាំងនៅដូចដើម មានព្រះបាទអជាតសត្រូវជាពុទ្ធសាសនូបត្ថម្ភក៏ ធ្វើចំនួន ៧ ខែ ទើបបានហើយស្រេច ព្រះពុទ្ធសាសនាក៏តាំងនៅមាំមួនបានជាយូរអង្វែង. តពីនោះមកបានសង្គាយនា ៤ ផងទៀត គឺសង្គាយនាទីពីរ ទីបី ទីបួន ទីប្រាំ (១) ។

ឯសង្គាយនាទី ២ ទី ៣ ទី ៤ នោះ មិនមែនប្លែកគ្នាអំពីសង្គាយនាទី ១ នោះប៉ុន្មានទេ គឺគ្រាន់តែផ្ទៀងផ្ទាត់ពុទ្ធវចនៈឲ្យត្រឹមត្រូវដូចបឋមសង្គាយនាប៉ុណ្ណោះ, ដល់មកសង្គាយនាទី ៥ ទើបមានការប្លែកគ្នាបន្តិច ព្រោះបានលើកពុទ្ធវចនៈចារឹកដាក់លើស្លឹករឹត ប៉ុន្តែនឹងមានតំណាលថា បានប្រែពុទ្ធភាសិតចាកបាលីមកជាសម្រាយ សូម្បីតែម្តងក៏ទេសោះ គ្រាន់តែបានផ្ទៀងផ្ទាត់ពុទ្ធវចនៈ គឺព្រះត្រៃបិដកនេះឲ្យត្រឹមត្រូវនៅដូចដើម និងប្រែចាកសីហឡភាសាមកជាមគធភាសា គឺភាសាបាលីប៉ុណ្ណោះ (២) ។

---

១- រឿងសង្គាយនានោះ មានសេចក្តីពិស្តារ នៅក្នុងគម្ពីរមហាវង្ស ។

២- ព្រះពុទ្ធឃោសាចារ្យ លោកទៅចម្លងព្រះត្រៃបិដក និង អដ្ឋកថាពីកោះលង្កា ប្រែចាកសីហឡភាសាមកជាមគធភាសា គឺភាសាបាលី ក្នុងរវាងពុទ្ធសករាជ ៩៥៦ ។

www.elibraryofcambodia.org

អស់លោកអ្នកដែលបានចាប់មើលសៀវភៅព្រះត្រៃបិដក គួរជ្រាបហេតុដែលជាការក្រលំបាកយ៉ាងអស្ចារ្យ ដូចបានរៀបរាប់មកហើយខាងដើមនោះ ឲ្យសព្វគ្រប់ទៅផង ទើបនឹងមានសេចក្តីរីករាយក្នុងចិត្ត រឹងរឹតតែកើតជ្រះថ្លាឡើងជាឧឡារភាពថែមទៀត ។

ដោយអំណាចនៃការសង្គាយនាផ្ទៀងផ្ទាត់ព្រះត្រៃបិដកដ៏ឧត្តមនេះ យើងសូមសំបូងសង្រួងឲ្យពុទ្ធិកសិក្សាក្នុងកម្ពុជរដ្ឋទាំងមូលនិងពុទ្ធសាសនបណ្ឌិត្យ មានអាយុយឺនយូរ និងតេជានុភាពចម្រើនរុងរឿងជាអង្វែងតទៅ !

ទីបំផុតនេះ សូមថ្វាយព្រះរាជកុសលមួយចំណែកចំពោះសម្តេច **ព្រះមហាក្សត្រិយានី** ជាអម្ចាស់ជីវិត និង សម្តេចព្រះ **នរោត្តម សីហនុ** ឧបយុវរាជ ព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជា និងមួយចំណែកទៀតចំពោះសម្តេចព្រះ **សង្ឃរាជ** គណៈមហានិកាយ(១) សម្តេចព្រះ [illegible] ធម្មយុត្តិកនិកាយ, សម្តេចព្រះ **ពោធិវង្ស**,(២) សម្តេចព្រះ **ធម្មឧទ្ទាធិបតី** មេគណខេត្តកំពង់ឆ្នាំង, ព្រះភិក្ខុសង្ឃព្រមទាំងអស់លោកគណៈរដ្ឋមន្ត្រីនិងពុទ្ធបរិស័ទក្នុងកម្ពុជរដ្ឋទាំងមូល សូមឲ្យបានឋិតនៅក្នុងសេចក្តីសុខចម្រើនជានិច្ចនិរន្តរ៍តរៀងទៅ !

**ក្រុមជំនុំព្រះត្រៃបិដក**

នៃ

វិជ្ជាបានពុទ្ធសាសនបណ្ឌិត្យ

(ក្រសួងធម្មការ)

www.elibraryofcambodia.org

---

១- ទ្រង់ចូលព្រះទិវង្គត កាលពីថ្ងៃព្រហស្បតិ ១៤ កើត ខែភទ្របទ ត្រូវនឹងថ្ងៃទី ២៥ កញ្ញា ១៩៦៩ វេលាម៉ោង ២០ និង ២០ នាទី ក្នុងព្រះជន្មាយុ ៨៦ ព្រះវស្សា ។

២- កាលនោះ សម្តេចមានព្រះឋានន្តរសក្តិ ជាសម្តេចព្រះពោធិវង្ស ។ ព្រះអង្គទទួលព្រះសមណសក្តិជា សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ ក្រោយការសោយព្រះទិវង្គតនៃសម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ដោយព្រះរាជក្រឹត្យលេខ ២៩ រ.វ ចុះថ្ងៃទី ២៣ កញ្ញា ១៩៦៩ ។

www.elibraryofcambodia.org

6026 08200693 006026 08

PAT
313/08/
WBC

294.307
LEW 596

រោងពុម្ពបណ្ណាគារ
រស្មីកម្ពុជា
លេខ ៦៨ វិថីប៉ាស្ទ័រ ភ្នំពេញ

www.elibraryofcambodia.org

តម្លៃ ១៥៛០០

www.elibraryofcambodia.org